# របាយការណ៍ប្រចាំត្រីមាសទី៤
# ឆ្នាំ ២០២៣

០១ តុលា - ៣១ ធ្នូ ២០២៣

## អរ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-000, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៤២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី៤ ឆ្នាំ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ | ៦០៨.១៥៩.៥៣០ |
| បំណុលសរុប | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ | ៣២២.២៤០.៨២០ |
| មូលធនក្រុមហ៊ុនសរុប | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ | ២៨៥.៩១៨.៧១០ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី ៤ ឆ្នាំ២០២៣ | ត្រីមាសទី ៤ ឆ្នាំ២០២២ | ត្រីមាសទី ៤ ឆ្នាំ២០២១ |
|---|---|---|---|
| ចំណូលសរុប | ៣១៥.២៥០.៣៤៦ | ៦៧០.៥១៧.០៩២ | ៣៦៨.១៤៩.៧៦៨ |
| ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ | (១៤.៩៤១.១៩៩) | ៧៨.៧៥៨.៥១៩ | ៤១.៥៨២.១៩៩ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | (១៣.០៧៥.៤៥៣) | ៦២.៧៥៨.៤៥០ | ៣៦.០២២.៣៥៩ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | (១៦.៥០៨.៨៨៩) | ៦៤.២០៨.១០៤ | ៣៥.៦៤៧.៤០៩ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី ៤ ឆ្នាំ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| អនុបាតសាធនភាព | ១,២ | ១,០ | ១,១ |
| អនុបាតចរន្ត (Current Ratio) | ២,៥ | ២,០ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ០,៦ | ០,៧ | ១,០ |

| អនុបាតចំណេញភាព | ត្រីមាសទី ៤ ឆ្នាំ២០២៣ | ត្រីមាសទី ៤ ឆ្នាំ២០២២ | ត្រីមាសទី ៤ ឆ្នាំ២០២១ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | -១,៧% | ៨,៦% | ៧,០% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | -៣,៥% | ១៧,៧% | ១៥,០% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,៧% | ១៩,៦% | ១៧,៩% |
| គម្លាតចំណេញ (Profit Margin) | -៥,២% | ៩,៦% | ៩,៧% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | (០,៧) | ១៦,០ | ១៨,៣ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសខ្មែរ










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
១១,២%
៩,៨%
២.២០៣.២៥៣.៤៥៣
១.៦២៦.៥៤០.០២៤
១.៨០០.៣៦២.០៩៤
៦,១%
២០២១
២០២២
២០២៣
ប្រាក់ចំណូល
ចំណូលសុទ្ធ%

## សមាជិកក្រុមប្រឹក្សាភិបាល



លោក Wiedmann Christian | លោក ខន សាំង | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

**ប្រធានក្រុមប្រឹក្សាភិបាល**

លោក ខន សាំង

**អភិបាលប្រតិបត្តិ**

លោក Tom Whitcraft

**អភិបាលមិនប្រតិបត្តិ**

លោក Wiedmann Christian

**អភិបាលមិនប្រតិបត្តិ**

លោក Ith Vichit

**អភិបាលឯករាជ្យ**

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") នៅក្នុងត្រីមាសទី៤ នៃឆ្នាំ ២០២៣។

សេដ្ឋកិច្ចពិភពលោកបានបង្ហាញពីភាពធន់ជាងការរំពឹងទុកនៅក្នុង ត្រីមាសទី៤ ឆ្នាំ២០២៣ ដោយ Euromonitor International បានព្យាករណ៍ថានឹងកើនឡើងបន្តិចនៃ GDP ពិភពលោកត្រឹមាសដល់ ២,៨% ពី ២,៦% នៅក្នុង ត្រីមាសទី៤ ឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយប្រទេសចិន ជាប្រទេសដែលមានសេដ្ឋកិច្ចទូលំទូលាយជាងគេបំផុតនៅអាស៊ី និងជាអ្នកវិនិយោគធំជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានទម្លាក់ចុះនូវការរំពឹងទុករបស់ខ្លួនព្រមគ្នាជាមួយនឹងកំណើន GDP ដោយបានធ្លាក់ចុះមកត្រឹម ៥,០% នៅឆ្នាំ២០២៣។ វិបត្តិវិស័យអចលនទ្រព្យដ៏ខ្លាំង រួមជាមួយនឹងការកង្វះការបញ្ជាទិញពីរោងចក្រផលិតកម្ម បានអង្រួនទំនុកចិត្តអតិថិជនដែលជាជនជាតិចិន។ បើមើលទៅតាមផ្លូវវិជ្ជមាន អ្នកសេដ្ឋកិច្ចមើលឃើញថាមានកំណើនខ្លាំងនៅក្នុងសេដ្ឋកិច្ចដែលកំពុងរីកចម្រើននៃអាស៊ីប៉ាស៊ីហ្វិក (វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី និងឥណ្ឌា)។ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីសក្តានុពលសេដ្ឋកិច្ចរបស់ប្រទេសជិតខាង។

ឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានប្រកាសអំពីផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលថ្មីសម្រាប់ការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងវេទិការការរដ្ឋាភិបាល-វិស័យឯកជនលើកទី១៩ កាលពីខែវិច្ឆិកា។ កម្លាំងចលករនៃគំនិតផ្តួចផ្តើមនេះ និងគំនិតផ្តួចផ្តើមផ្សេងទៀតត្រូវបានគេរំពឹងថានឹងទទួលបានផ្លែផ្កានៅឆ្នាំ ២០២៤ ។

នៅក្នុងត្រីមាសទី៤ ឆ្នាំ ២០២៣ ទីផ្សារយានយន្តនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំ ២០២២។ ទិន្នន័យនេះទទួលបាន បន្ទាប់ពីការធ្លាក់ចុះកាន់តែខ្លាំងនៅក្នុងត្រីមាសទី៣ (-៥៦% បើធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំ ២០២២)។ ការកាត់បន្ថយអត្រានៃការអនុម័តសម្រាប់កម្ចីធនាគាររបស់អតិថិជន និងអត្រាការប្រាក់ខ្ពស់បានធ្វើឱ្យប៉ះពាល់ដល់ការចំណាយក្នុងស្រុក។ ក្តីសង្ឃឹមទៅលើកំណើនទេសចរណ៍ ក្រោយរដូវកាលកូវីដ នៅតែមិនទាន់បានសម្រេចនៅឆ្នាំ ២០២៣។

RMAC មានមោទនភាពដែលនៅឆ្នាំ ២០២៣ យានយន្តដែលលក់បានភាគច្រើន គឺត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ផ្នែកឧបករណ៍កសិកម្មរបស់យើងដែលចែកចាយផលិតផល John Deere ទទួលបានចំណែកទីផ្សារ និងប្រាក់ចំណេញឡើងវិញនៅក្នុងឆមាសទីពីរនៃឆ្នាំនេះ ចំណែកឯការចែកចាយរថយន្ត Chang An របស់យើងបានចាប់ផ្តើមលេចឡើងនូវលទ្ធផលល្អ។

នៅក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ២០២៣ ក្រុមហ៊ុន RMAC បានទទួលកំណត់ត្រាការលក់ទាបជាង -៥៣% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំ ២០២២ ដែលបានឈានដល់កម្រិតកំពូលជាប្រវត្តិសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ពីមួយឆ្នាំទៅមួយឆ្នាំ ក្រុមហ៊ុន RMAC នៅតែរក្សាការនាំមុខទីផ្សារយានយន្តលក្ខណៈគ្រួសារ នៅក្នុងចំណែកទីផ្សារនៃផ្នែករថយន្តលក្ខណៈគ្រួសារជាមួយនឹងម៉ូដែល Ford និង Changan ។ រវាងការកើនឡើងនៃតម្លៃផ្សេងៗ និងការកើនឡើងនៃអត្រាការប្រាក់កាន់តែខ្ពស់ ការចំណាយបានកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងរយៈពេលស្រដៀងគ្នាក្នុងឆ្នាំ ២០២២។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននៅតែទទួលបានប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធរួច ចំនួន ១១៣ ប៊ីលានរៀល សម្រាប់ឆ្នាំនេះ។

RMAC បន្តខិតខំប្រឹងប្រែងក្នុងការផ្តល់ជូននូវផលិតផលទៅតាមតម្រូវការរបស់អតិថិជន ក៏ដូចជាសេវាកម្មដែលមិនអាចប្រៀបផ្ទឹមបានដល់អតិថិជនដ៏ស្មោះត្រង់របស់ខ្លួន។ សព្វថ្ងៃអាជីវកម្មសេវាកម្មបន្ទាប់ពីការលក់របស់យើងបានបង្កើនប្រាក់ចំណូលរបស់ពួកគេចំនួន +១៩% ក្នុងអំឡុងពេលពេញមួយឆ្នាំដែលបង្ហាញថាអតិថិជនរបស់យើងឱ្យតម្លៃទៅលើគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មរបស់យើង។ ទន្ទឹមនឹងនេះដែរ យើងកំពុងវិនិយោគឥតឈប់ឈរនៅក្នុងបណ្តាញរបស់យើងជាមួយនឹងការពង្រីកបន្ថែមនូវបណ្តាញមជ្ឈមណ្ឌលសេវាកម្មក្រោយការលក់។

ក្នុងអំឡុងត្រីមាសនេះ RMAC ទទួលបានការទទួលស្គាល់ជាអន្តរជាតិដោយការទទួលបានពានរង្វាន់ជា "ក្រុមហ៊ុនឈានមុខក្នុងវិស័យការងារនៅអាស៊ី ដែលបង្ហាញពីស្តង់ដារខ្ពស់ដែលបុគ្គលិករបស់យើងសម្រេចបាន និងគុណភាពនៃបរិយាកាសការងាររបស់ពួកគេ។

ជាមួយគ្នានេះដែរ ខ្ញុំមានមោទនភាពយ៉ាងខ្លាំងក្នុងការប្រកាសថា RMAC បានទទួលរង្វាន់ជា "អ្នកឈ្នះពានរង្វាន់ CSR ឧត្តមភាពក្នុងវិស័យអប់រំ" ដែលផ្តល់ដោយសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ដោយទទួលស្គាល់ការខិតខំប្រឹងប្រែង និងការវិនិយោគទាំងអស់ដែលក្រុមហ៊ុនបានធ្វើចំពោះគ្រប់សាកលវិទ្យាល័យ និងសាលាវិជ្ជាជីវៈនានា។

ជាចុងក្រោយ RMAC ទទួលបានការបន្តនូវវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាសរបស់ខ្លួនដែលគ្របដណ្តប់ឆ្នាំ ២០២៤ និង ២០២៥ ពីអគ្គនាយកដ្ឋានពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ការបន្តនូវវិញ្ញាបនបត្រនេះបង្ហាញពីការអនុលោមយ៉ាងរឹងមាំរបស់ក្រុមហ៊ុនរបស់យើងជាមួយនឹងច្បាប់ពន្ធដាដែលបានចូលជាធរមាន។

ខ្ញុំបាទតំណាងឱ្យក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន សូមថ្លែងអំណរគុណចំពោះអតិថិជនជាទីស្រឡាញ់ទាំងអស់ដែលបានគាំទ្រដល់ក្រុមហ៊ុនយើងក្នុងគ្រាមានអាសន្ន ដើម្បីព្រះរាជាណាចក្រកម្ពុជាកន្លងមក។

យើងក៏សូមជូនពរឱ្យប្រជាជនកម្ពុជាទាំងអស់មានសុខសុវត្ថិភាព និងសុខភាពល្អគ្រប់ៗគ្នានៅក្នុងឆ្នាំ២០២៤។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

## មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ 3
ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ........ 5
សមាជិកក្រុមប្រឹក្សាភិបាល ........ 7
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ 8
ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ........ 11
ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ........ 11
ខ .សកម្មភាពអាជីវកម្ម ........ 11
គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ........ 12
ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ 13
ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក ........ 13
ខ .រចនាសម្ព័ន្ធប្រាក់ចំណូល ........ 13
ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ........ 14
ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ........ 15
ក .ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 15
ខ .កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ........ 16
គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ........ 16
ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ........ 16
ង. ផលប៉ះពាល់នៃអតិផរណា ........ 16
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ........ 16
ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ........ 16
ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ........ 17

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៤២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, Changan, After-Sales of Mercedes-Benz, John Deere, TCM, JCB, FUSO, Changan និង Piaggio។ ថ្មីៗនេះ RMAC បានដាក់ឱ្យដំណើរការនូវផ្នែកថ្មីមួយដែលមានឈ្មោះថា គ្រឿងបន្លាប់រថយន្ត (Automobile Acccessories) ក្នុងគោលបំណងលក់ថ្នាំលាបរថយន្តដែលមានគុណភាពខ្ពស់សម្រាប់ការងារផ្នែកជួសជុលតួរឡាន ក្រោមម៉ាក R-M (ជាផ្នែកមួយនៃក្រុមហ៊ុន BASF Group) និងអាគុយរថយន្ត ក្រោមម៉ាកយីហោក្ល RG Batteries ។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោមៈ

### ខែធ្នូ ឆ្នាំ ២០២៣

**Land Rover ចូលរួមជាមួយ ក្រសួងពាណិជ្ជកម្ម ក្នុងពិព័រណ៌ នាំចូល-នាំចេញ**

RMAC បានចូលរួមជាមួយ ក្រសួងពាណិជ្ជកម្ម ក្នុងពិព័រណ៍ផលិតផលកម្ពុជា និងពិព័រណ៍ទំនិញនាំចូល នាំចេញលើកទី១៦។




### ពានរង្វាន់នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣

**RMAC ទទួលបានពានរង្វាន់ AMCHAM CSR ឧត្តមភាពនៅក្នុងវិស័យអប់រំ**

RMAC បានស្ថាបនាមជ្ឈដ្ឋានគ្រឹះសម្រាប់មនុស្សជំនាន់ក្រោយ។




**RMAC ទទួលបានពានរង្វាន់ ក្រុមហ៊ុនឈានមុខ ក្នុងវិស័យការងារនៅក្នុងអាស៊ី**

រយៈពេលពីរឆ្នាំជាប់គ្នាហើយដែល RMAC បានឈ្នះពានរង្វាន់ដ៏មានកិត្យានុភាព ដែលបញ្ជាក់ពីភាពប្តេជ្ញាចិត្តចំពោះបុគ្គលិករបស់យើង។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

នៅកំឡុងត្រីមាសទី៤ នៃឆ្នាំ២០២៣ គឺជាកំឡុងពេលដែលពោរពេញទៅដោយបញ្ហាប្រឈមយ៉ាងច្រើននៅក្នុងវិស័យយានយន្តនៅកម្ពុជា ដែលបានធ្លាក់ចុះ -៣៦% ធៀបទៅនឹងត្រីមាសទី៤ នៃឆ្នាំ២០២២។

នៅក្នុងបរិបទលំបាកបែបនេះ, RMAC ទទួលបានសមិទ្ធិផលសំខាន់ៗនៅចុងត្រីមាសទី៤ នៃឆ្នាំ២០២៣ រួមមាន៖

**ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖**

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងផ្នែករថយន្ត Pick-up ក្នុងប្រទេសកម្ពុជា។ យើងពិតជាមានមោទនភាពដែលយានយន្តដែលលក់បានភាគច្រើនត្រូវបានផលិតក្នុងប្រទេសកម្ពុជា។

**គ្រឿងចក្រម៉ាក John Deere៖** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន រថយន្តម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា ហើយបានដណ្តើមយកចំណាត់ថ្នាក់ទីផ្សារវិញក្នុងកំឡុងឆ្នាំ ២០២៣។

**លទ្ធផលហិរញ្ញវត្ថុ៖**

ដោយសារតែស្ថានភាពទីផ្សារក្នុងវិស័យយានយន្តនៅកម្ពុជាមិនសូវល្អ, ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ៣១៥ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣ ដែលមានការធ្លាក់ចុះចំនួន -៥៣% ធៀបនឹងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២២។ សម្រាប់ដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ១៣,១ ប៊ីលានរៀល (ធ្លាក់ចុះ-១២០,៨% បើប្រៀបធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២២)។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១៩ប៊ីលានរៀល ក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

### ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី៤ ឆ្នាំ២០២៣ និងរយៈពេលប្រៀបធៀបកាលពីឆ្នាំមុន។

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី៤ ឆ្នាំ២០២២ | ភាគរយ | ត្រីមាសទី៤ ឆ្នាំ២០២១ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ២៩៦.៧៥៥.២៩០ | ៩៤,១% | ៦៥២.០៦៩.០៨៣ | ៩៧,២% | ៣៥៨.៧៥៩.៧៥២ | ៩៧,៤% |
| **ចំណូលនៃសេវាកម្ម** | ១៨.៤៩៥.០៥៦ | ៥,៩% | ១៨.៤៤៨.០០៩ | ២,៨% | ៩.៣៩០.០១៦ | ២,៦% |
| **សរុប** | ៣១៥.២៥០.៣៤៦ | ១០០,០% | ៦៧០.៥១៧.០៩២ | ១០០,០% | ៣៦៨.១៤៩.៧៦៨ | ១០០,០% |

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៣១៥,៥ ប៊ីលានរៀល ធ្លាក់ចុះចំនួន -៣៥៥,៣ ប៊ីលានរៀល ឬ -៥៣% ភាគរយ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ បើធៀបនឹងត្រីមាសក្នុង ឆ្នាំ២០២២។

### ២. ផ្នែកនៃចំណូល

ផ្នែករថយន្ត Ford និង Land Rover ត្រូវទទួលបានការប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងនៃការធ្លាក់ចុះចំណូលនៅក្នុងត្រីមាស៤ ឆ្នាំ២០២៣ បើធៀបទៅនឹងឆ្នាំមុន ខណៈពេលដែលរថយន្តម៉ាក Changan, គ្រឿងចក្រកសិកម្ម (Agriculture) គ្រឿងចក្រធនធ្ងន់ (Heavy-Equipment) និងផលិតផលពិសេសរបស់ RMA ទទួលការកើនឡើងកំណត់ត្រាខ្លាំងជាងឆ្នាំមុន។

### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ៣១៥.២៥០.៣៤៦ | ៦៧០.៥១៧.០៩២ | (៣៥៥.២៦៦.៧៤៦) | -៥៣,០% |
| **ចំណេញដុល** | ៤៩.៤៩៧.៨២៩ | ១៣១.៥៥៤.៣៤៥ | (៨២.០៥៦.៥១៦) | -៦២,៤% |
| **គម្លាតចំណេញដុល** | ១៥,៧% | ១៩,៦% | | |
| **ចំណាយ** | ៥៥.៨១៦.៦៧២ | ៤៧.៥៣៦.៣៤៣ | ៨.២៨០.៣២៩ | ១៧,៤% |
| **ចំណាយហិរញ្ញវត្ថុ** | ៨.៦២២.៣៥៦ | ៥.២៥៩.៤៨៣ | ៣.៣៦២.៨៧៣ | ៦៣,៩% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | (១៤.៩៤១.១៩៩) | ៧៨.៧៥៨.៥១៩ | (៩៣.៦៩៩.៧១៨) | -១១៩,០% |
| **គម្លាត** | -៤,៧% | ១១,៧% | | |

### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ២០២៣ | ត្រីមាសទី៤ ឆ្នាំ ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ប្រាក់ចំណេញមុនបង់ពន្ធ** | (១៤.៩៤១.១៩៩) | ៧៨.៧៥៨.៥១៩ | (៩៣.៦៩៩.៧១៨) | -១១៩,០% |
| **ចំណាយពន្ធ** | (១.៨៦៥.៧៤៦) | ១៦.០០០.០៦៩ | (១៧.៨៦៥.៨១៥) | -១១១,៧% |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** | (១៣.០៧៥.៤៥៣) | ៦២.៧៥៨.៤៥០ | (៧៥.៨៣៣.៩០៣) | -១២០,៨% |
| **គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ** | **-៤.១%** | **៩,៤%** | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងស្តុកទុកនូវធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២២ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលថ្មីត្រូវបានបោះឆ្នោតជ្រើសរើសនៅខែសីហា ឆ្នាំ២០២៣។ ការផ្លាស់ប្តូរអ្នកដឹកនាំបានបង្ហាញពីភាពរឹងមាំ រួមជាមួយនឹងភាពបត់បែន។ ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលវិញ គឺមិនត្រូវបានរំពឹងថានឹងមានការផ្លាស់ប្តូរក្នុងរយៈពេលដ៏ខ្លីខាងមុខនេះទេ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ១៤ កុម្ភៈ ២០២៤

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

